# បណ្ដាំឪពុកម្ដាយ



# បណ្ដាំឪពុកម្ដាយ

កូនស្រីមាសឪពុក, ឪពុកម្ដាយបានចិញ្ចឹមកូនតាំងពីតូចរហូតដល់ធំ ដោយក្ដីព្យាយាមបំផុតក្នុងនោះមានទាំងយំ មានទាំងសើច មានទាំងដើរ មានទាំងរត់ មានទាំងដេកលក់ មានទាំងអត់ឃ្លាន ពោលគឺ ឪពុកម្ដាយបានឆ្លងកាត់រាល់ការលំបាកវេទនាជាច្រើនរាប់មិនអស់ឡើយ ។ គ្រប់រសជាតិល្វីងជូរចត់កំសត់អត់ឃ្លាន មានទាំងអស់ ព្រោះឪពុកម្ដាយរបស់កូន សុទ្ធតែជាកូនកំព្រាឪពុកដូចគ្នា គឺដោយសារពួកប៉ុលពតសម្លាប់ជីតារបស់កូនដោយហេតុថាពួកគាត់ (**ហ៊ុន គឿង** និង **សួន ផេង** ) ជីតារបស់កូនធ្លាប់ជាមន្ត្រីរាជការក្នុងសម័យ **ព្រះមហាក្សត្រ នរោត្តមសីហនុ** ។ ដូច្នេះរសជាតិនៃកូនកំព្រាដែលឪពុកនិងម្ដាយរបស់កូនបានទទួលគឺ សែនលំបាកវេទនាណាស់ គឺមិនអាចរៀបរាប់និងថ្លែងអោយអស់បានឡើយ ។ ឪពុកម្ដាយនិយាយនេះគ្រាន់តែចង់ប្រាប់កូនថា ទោះបីជាកូនជួបការលំបាកខ្លះៗ ដែលកូនបានកើតមកជាកូនរបស់ប៉ាម៉ាក់ ( **អេាភ ប៊ូរ៉ា** និង **សួន សុគន្ធា** )ក៏ពិតមែន តែកូននៅតែមានកង់ជិះ ឬ

ម៉ូតូជិះ ជួនកាលប៉ាជូនទៅសាលា ហើយមានលុយកាក់សម្រាប់ទៅរៀនខ្លះដែរ ទោះជាមិនគ្រប់គ្រាន់តាមតម្រូវការក៏ដោយចុះ ។ ចំណែកប៉ា និងម៉ាក់របស់កូនវិញគ្មានទាំងកង់ជិះទៅរៀនទៅទៀតគឺ ដើរទៅរៀន គ្មានទាំងលុយសម្រាប់ចាយនៅសាលាដូចពួកកូនៗឡើយ ។ រាល់ថ្ងៃមុនពេលទៅរៀនគឺ ហូបបាយកកជាមួយទឹកត្រី ជាមួយប្រហុកជាមួយផ្អក ជាមួយស្ករ ជាមួយត្រីប្រឡាក់ ។

ក្រោយពីប៉ា និងម៉ាក់បានរៀបការគ្នាជាប្តីប្រពន្ធរួមមកគឺ មានតែកង់កញ្ចាស់ ១ ប៉ុណ្ណោះសម្រាប់ជិះទៅធ្វើការផងទៅបង្រៀនភាសាអង់គ្លេសផង ទៅលក់ផ្លែមាន ផ្លែទៀបផ្លែចេកនៅផ្សារអូរឫស្សី ផ្សារដើមគផង ។ ប៉ាខំធ្វើការរដ្ឋផង ឆ្លៀតពេលក្រៅម៉ោងធ្វើការ ទៅបង្រៀនភាសាអង់គ្លេសតាមសាលាផង និងតាមផ្ទះផង ហើយពេលយប់ឆ្លៀតយកសាទីតកុន (ខ្សែភាពយន្តរឿងភាគជាភាសាអង់គ្លេស ) មកបកប្រែជាភាសាខ្មែរនៅផ្ទះបន្ថែមទៀត តែនៅតែមានការខ្វះខាត ព្រោះតែប៉ានិងម៉ាក់មានកូនច្រើននាក់ (៨នាក់) ដូចកូនដឹងស្រាប់ហើយការចំណាយនោះគឺ មានច្រើនមុខ

ដូចជាការស្លៀកពាក់ ការហូបចុក ការសិក្សា ការឈើថ្កាត់ ។ល។

កូនជាទីស្រលាញ់របស់ប៉ាម៉ាក់ ឥឡូវនេះកូនធំហើយ តែប៉ានិងម៉ាក់នៅតែស្រលាញ់កូនរហូតដោយមិនប្រែប្រួលចិត្តឡើយ ។ ហើយពេលនេះគឺជាពេលសមល្មមដែលត្រូវម៉ែទុកឪពុកដាក់រៀបចំឲ្យមានគូស្រករ មានប្តីទៅតាមប្រពៃណីរបស់ខ្មែរយើងក្នុងកាលដ៏សមគួរនេះបានហើយ ។ ដូច្នេះប៉ានិងម៉ាក់សូមអរគុណកូនស្រីយ៉ាងខ្លាំងចំពោះទង្វើល្អរបស់កូនតាំងពីតូចរហូតដល់ធំដែលកូនមិនបានបង្កបញ្ហាលំបាកខុសច្បាប់ណាមួយឲ្យឪពុកម្តាយដោះស្រាយនោះឡើយ។ ពិសេសជាងនេះទៅទៀតគឺ កូនបានថែរក្សាខ្លួនបានល្អ ថែរក្សាប្រពៃណីបានល្អពោលគឺ កូនបានរក្សាកិត្តិយសឪពុកម្តាយ និងពូជពង្សវង្សត្រកូលបានល្អ ។ ទាំងអស់នេះដែលឪពុកម្តាយគ្រប់រូបចង់បាន ហើយសង្គមក៏ត្រូវការ ។ ពេលនេះ កូនទទួលការអនុញ្ញាតិពីឪពុកម្តាយទាំងសងខាងឲ្យកូនរៀបមង្គលការប្រកបដោយកិត្តិយសដ៏ខ្ពង់ខ្ពស់សម្រាប់ខ្លួនឯងផង និងសម្រាប់គ្រួសារផង ។

កូនអើយ!   ក្រោយពីរៀបមង្គលការរួចហើយកូននឹងក្លាយជាភរិយារបស់គេហើយបានសេចក្តីថា កូនធំហើយ គឺលែងជាក្មេងស្រីនៅក្នុងបន្ទុកឪពុកម្តាយទៀតហើយ ។ ដូច្នេះកូនត្រូវតែរឹងមាំហើយផ្លាស់ប្តូរអត្តចរិត  ផ្លាស់ប្តូរគំនិត  ពីក្មេងមកចាស់   ពីទម្លាប់នៅជាមួយឪពុកម្តាយទៅនៅជាមួយប្តី ដូច្នេះកូនត្រូវបំពេញកាតព្វកិច្ចជាភរិយាល្អដូចខាងក្រោម៖

- ទី១. កូនត្រូវចាត់ចែងការងារក្នុងផ្ទះក្រៅផ្ទះឲ្យបានល្អ ។
- ទី២. កូនត្រូវស្មោះត្រង់នឹងស្វាមីមិនត្រូវប្រព្រឹត្តក្បត់ចិត្តស្វាមីឡើយ ។
- ទី៣. កូនត្រូវសង្គ្រោះញាតិទាំងសងខាង ។
- ទី៤. កូនត្រូវថែទាំទ្រព្យដែលប្តីរកបាន ។
- ទី៥. កូនត្រូវឈ្លាសវៃ រហ័សរហួន
- ទី៦. កូនមិនត្រូវខ្ជិលច្រអូស ឬ មាយាឡើយ ។
- ទី៧. កូនមិនត្រូវនិយាយកុហកឡើយ ។

ក្រោយពីបានគោរពតាមតួនាទីជាភរិយាល្អរួចហើយកូនត្រូវប្រតិបត្តិតាមឱវាទឪពុកម្តាយទាំង ១៧ចំណុចបន្តទៀត៖

ទី១. កូនមិនត្រូវនាំរឿងពីក្នុងផ្ទះ (រឿងប្ដីប្រពន្ធខ្លួនឯង) ទៅប្រាប់អ្នកដទៃ ទៅប្រាប់ញាតិមិត្ត ទៅប្រាប់ឪពុកម្ដាយនោះទេ្បីយគឺ ព្យាយាមដោះស្រាយខ្លួនឯងឲ្យអស់លទ្ធភាព ។

ទី២. កូនមិនត្រូវនាំរឿងពីក្រៅផ្ទះមកប្រាប់អ្នកក្នុងផ្ទះអោយដោះស្រាយនោះទេ្បីយ ហើយបើមានពាក្យញុះញង់ ឬ ពាក្យអុជអាលរបស់អ្នកដទៃ កូនត្រូវរក្សាពាក្យនោះឲ្យស្ងាត់បាត់ត្រឹមកូនណាកូនណា។

ទី៣. កូនត្រូវជាអ្នកមានសទ្ធាចំពោះព្រះពុទ្ធសាសនា ហើយបរិច្ចាគទ្រព្យធ្វើជាទានចំពោះឪពុកម្ដាយ ចំពោះអ្នកមានសីល ចំពោះអ្នកក្រទៅតាមលទ្ធភាពជាក់ស្ដែងរបស់កូនឲ្យបានរឿយៗ ។

ទី៤. បើកូនមានប្រាក់ ចូរឲ្យគេខ្ចីចំពោះអ្នកដែលខ្ចី ហើយសងវិញតាមកាលកំណត់ តែមិនត្រូវឲ្យអ្នកខ្ចីមិនសងតាមកាលកំណត់នោះទេ្បីយ ។

ទី៥. កូនត្រូវចូលគេងក្រោយប្ដី តែត្រូវភ្ញាក់ ហើយក្រោកមុនប្ដី ។

ទី៦. កូនត្រូវស្ដាប់ប្ដីនិយាយដោយយកចិត្តទុកដាក់ ហើយធ្វើតាមឲ្យបានល្អ ។

ទី៧. កូនត្រូវស្ដាប់ឪពុកម្ដាយក្មេកដោយគោរពហើយប្រតិបត្តិតាម ។

ទី៨. កូនមិនត្រូវមើលងាយប្ដី ឬ តមាត់ប្ដី និងឪពុកម្ដាយក្មេកឡើយ ។

ទី៩. កូនមិនត្រូវនិយាយឡេះឡោះ លេងសើចដែលជាពាក្យរោយរាយឥតបានការនោះឡើយ ។

ទី១០. កូនត្រូវអត់ធ្មត់នឹងពាក្យសម្ដីរបស់ប្ដី ឬ ឪពុកម្ដាយក្មេកដែលនិយាយមិនល្អ ។

ទី១១. កូនត្រូវគោរពប្ដីឲ្យដូចជាឪពុក ហើយគោរពឪពុកម្ដាយក្មេកឲ្យដូចជាព្រះ ។

ទី១២ កូនត្រូវថែទាំជូតសម្អាតផ្ទះ និង បោកអ៊ុតខោអាវប្ដីឲ្យបានល្អ។

ទី១៣. កូនត្រូវហូបបាយក្រោយប្ដី ឬ ក្រោយឪពុកម្ដាយក្មេក គឺត្រូវធ្វើដូចជាម្ដាយរបស់កូនអញ្ចឹង

ព្រោះម៉ាក់គាត់តែងតែហូបក្រោយប្ដីនិងក្រោយ
កូនៗទៅទៀត ភាគច្រើនគឺគាត់ហូបរបស់សល់
សម្លសល់ពីប្ដីពីកូនប៉ុណ្ណោះ ។

ទី១៤. កូនត្រូវឈប់ផឹកគ្រឿងស្រវឹង ព្រោះឥឡូវមាន
ប្ដីហើយ ត្រូវធ្វើខ្លួនឲ្យសមជាភរិយាល្អ និងត្រៀម
ខ្លួនធ្វើជាម្ដាយល្អរបស់កូនៗ ។

ទី១៥. កូនមិនត្រូវដើរទៅផ្ទះអ្នកជិតខាងដោយមិនមាន
ការចាំបាច់នោះឡើយ ។

ទី១៦. កូនត្រូវសុំការអនុញ្ញាតិពីប្ដី ឬ ពីឪពុកម្ដាយក្មេក
ជាមុនសិន មុននឹងទៅទីណា ឬ កន្លែងណា
១ថ្ងៃ ២ថ្ងៃ ។ល។

ទី១៧. កូនត្រូវចាយវាយប្រាក់សម្រាប់តែរបស់ណាចាំ
បាច់ប៉ុណ្ណោះ ហើយបើរបស់ណាមានតម្លៃរាប់
រយដុល្លាឡើងទៅកូនត្រូវពិភាក្សាជាមួយប្ដីជា
មុនសិន។ កូនជាទីស្រលាញ់របស់ប៉ាម៉ាក់ បើកូន
ធ្វើតាមបណ្ដាំឪពុកម្ដាយបានកូននឹងមានសេចក្ដី
សុខមានសុភមង្គលមានកិត្តិយសខ្ពង់ខ្ពស់ រស់

នៅថ្ងៃថ្ងៃមានគេគោរពរាប់អានច្រើន  មានគេស្រលាញ់ចូលចិត្តច្រើន  កូននឹងចម្រុងចម្រើនលូតលាស់ត្រដឹមត្រដែតត្រសៃតឡើងដោយអំពើល្អនេះជាមិនខានឡើយ ។

ធ្វើនៅថ្ងៃ ៦រោច ខែផល្គុន ព.ស ២៥៦០

ត្រូវនឹងថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៧

ហត្ថលេខា និងស្នាមមេដៃឪពុកម្តាយ

ឯកឧត្តម **អោក ប៉ូរ៉ា** និងលោកជំទាវ **ស្ងួន សុគន្ធា**

# គុណមាតា បិតា

## បទកាកគតិ ( កាព្យរាយ)

\+ បណ្ឌិតពោលថា មាតាបិតា
មានគុណខ្លាំងណាស់ គុណនោះសែនធំ
ជាងសុវណ្ណគិរី ធ្ងន់ដូចធរណី
កាត់ថ្លៃមិនបាន ។

\+ បើយើងរាប់គុណ តាំងពីទម្ងន់
មានគភ៌ក្នុងផ្ទៃ ម្ដាយចាញ់ខ្លាំងណាស់
អស់កម្លាំងល្វិតល្វៃ ទន់ជើងទន់ដៃ
ហូបអ្វីមិនកើត ។

\+ ដល់ពេលឈប់ចាញ់ ម្ដាយគិតទោម្និញ
រឿងថៃទាំផ្ទៃ តាំងពីមួយខែ
មិនហ៊ានធ្វើអ្វី ទោះហូបចំណី
ក៏ត្រូវប្រយ័ត្ន ។

\+ ពេលនៅក្នុងផ្ទៃ ៩ខែដប់ថ្ងៃ
គ្មានដឹងអ្វីសោះ ធាក់ដោលបុករុក
ឥតសល់ចន្លោះ ពោះម្ដាយស្មើរផ្ទុះ
ដោយសារតែកូន ។

\+ ពេលប្រសូតិបុត្រ ទុក្ខប៉ុនសមុទ្រ
ស្មើរសូន្យសង្ខារ ឈាមម្ដាយហូរធ្លាក់
ចេញពីកាយា ព្រោះបុត្រធីតា
ម្ដាយឈឺខ្លាំងណាស់ ។

\+ ពេលកូនកើតហើយ ឱម្ដាយខ្ញុំអើយ
ខំថែរក្សា ចិញ្ចឹមបីបាច់
ឱបនឹងឱរ៉ា លាមកយ៉ាងណា
ក៏មិនខ្ពើមដែរ ។

\+ ពេលកូនបៅដោះ ឈាមម្ដាយស្មើរខ្សោះ
អស់ពីអង្គប្រាណ តែម្ដាយពេញចិត្ត
នឹងបុត្រកល្យាណ ទោះបីក្ស័យប្រាណ
ក៏ម្ដាយហ៊ានប្ដូរ ។

+ បុត្រ បន្ទោបង់ ម្ដាយយកដៃក្បង់
កើបចេញចោលឆ្ងាយ គ្មានខ្ពើមរអើម
ហើយមិនជិនណាយ ទោះពេលហូបបាយ
ក៏ម្ដាយឥតខ្ពើម ។

+ ឱព្រះបិតា ទោះក្រមេ្តចម្ដា
ស្រវាស្រទេញ ស៊ីឈ្នួលជួលពាត់
រកប្រាក់ចំណេញ អោយកូនបំពេញ
ក្នុងការសិក្សា ។

+ ក្នុងនាមបិតា ក្រខ្សត់យ៉ាងណា
បិតាមិនស្ដី លាក់ទុក្ខក្នុងចិត្ត
ក្រៀមក្រំរាល់ថ្ងៃ ព្រោះខ្លាចបុត្រថ្លៃ
មិនស្មើនឹងគេ ។

+ មាតាបិតា បុត្រដើរទៅណា
នេត្រាគយគន់ ដើរជិតដើរឆ្ងាយ
ខ្វល់ខ្វាយមើលផ្លូវ ខ្លាចដំណើរទៅ
សុខទុក្ខមិនដឹង ។

+ មាតាបិតា បើបុត្រធីតា
គោរពអោយច្បាស់ បុណ្យនេះប្រាកដ
អោយផលក្រៃក្រាស់ ព្រោះលោកជាព្រះ
នៃកូនប្រុសស្រី ។

+ ឱកូនប្រុសស្រី បាយទឹកចំណី
ម្ហូបប្រៃម្ហូបសាប ចូរផ្គត់ផ្គង់គាត់
បង្អែមចង្ហាប នេះជាឱវាទ
នៃព្រះសម្ពុទ្ធ ។

+ មាតាបិតា ព្រះពុទ្ធដីកា
ថាគុណអនន្ត ធ្វើបុណ្យបានច្រើន
អនេកកប្បគុណ តែកុំអោយស៊ុន
ភាន់ទៅធ្វើបាប ។

+ មាតាបិតា បើបុត្រធីតា
ធ្វើគុណបានបុណ្យ តែបើធ្វើខុស
ទោសច្រើនអនន្ត នរកច្រើនជាន់
មិនងាយរួចឡើយ

(ចប់) សូមអនុមោទនា

# ធ្វើបុណ្យទាន់ថ្ងៃរះ

(កាព្យរាយ)

\+ ឱន  កាយ ថ្វាយ បង្គំ ប្រជុំ បី
ព្រះរតនត្រៃ ដ៏ ថ្លៃ ក្នុង លោក
ព្រះពុទ្ធ ព្រះធម៌ មាន សិរី ជោគ
សិទ្ធី លាភ ភោគ ដឹង គុណ ពុក ម៉ែ ។

\+ កូន អើយ លៃ លក រក នំ ចំណី
ជូន ពុក ម៉ែ ឆី ទាន់ ថ្ងៃ នៅ រះ
គុណ ឪពុក ម្ដាយ គុណ ធ្ងន់ ដូច ព្រះ
សូម កូន សំពះ គោរព បូជា ។

\+ ពេល ឥឡូវ នៅ ឃ្លាន ហើយ ហូប បាន
សូម បុត្រ កល្យាណ ជូន គាត់ ពិសា
បាន ឃើញ ផ្ទាល់ ផ្លែក បុណ្យ ច្រើន អស្ចារ្យ
ទើប បុត្រ ធីតា ចម្រើន រុង រឿង ។

\+ កូន ណា បាន ធ្វើ កូន នោះ បាន បុណ្យ
សូម កុំ ទម្រន់ ចាំ មើល បង ប្អូន
បើ មាន សំណាង នៅ មាន ជីដូន
សូម បុត្រ មាស ស្ងួន ជួយ ថែ រក្សា ។

\+ បុណ្យ ប្អូក និង បុណ្យ ធ្ងន់ ដូច ភ្នំ មាស
កូន ណា រវាស ភ្នំ មាស ឱ្យ ទ្រព្យ
ថែ ថ្នួន ឱ្យ ល្អ បវរ គួរ គាប់
កូន នឹង មាន ភ័ព្វ ជាប់ ឈ្មោះ កូន ល្អ ។

\+ មើល ថែ ពុក ម៉ែ ជីដូន ជីតា
ទេវតា រក្សា បាច ផ្កា ជូន ពរ
មង្គល សួស្តី សិរី បវរ
ព្រះឥន្ទ អបអរ សាទរ ឱ្យ លាភ ។

\+ កុំ ចាំ គាត់ ឈឺ ឬ កម្លាំង ខ្សោយ
យក នំ ទៅ ឱ្យ បាយ ទឹក ចំណី
គាត់ ហូប មិន កើត មាន ប្រយោជន៍ អ្វី
កូន ប្រុស កូន ស្រី ទិញ ទាំង អស់ គ្នា ។

\+ កូន ណា បាន ធ្វើ កូន នោះ បាន បុណ្យ
សូម កុំ ទម្រន់ ចាំ មើល បង ប្អូន
បើ មាន សំណាង នៅ មាន ជីដូន
សូម បុត្រ មាស ស្ងួន ជួយ ថែ រក្សា ។

\+ បុណ្យ បូក និង បុណ្យ ធ្ងន់ ដូច ភ្នំ មាស
កូន ណា វាស ភ្នំ មាស ឱ្យ ទ្រព្យ
ថែ ជួន ឱ្យ ល្អ បវរ គួរ គាប់
កូន នឹង មាន ភ័ព្វ ជាប់ ឈ្មោះ កូន ល្អ ។

\+ មើល ថែ ពុក ម៉ែ ជីដូន ជីតា
ទេវតា រក្សា បាច ផ្កា ជូន ពរ
មង្គល សួស្តី សិរី បវរ
ព្រះឥន្ទ អបអរ សាទរ ឱ្យ លាភ ។

\+ កុំ ចាំ គាត់ ឈឺ ឬ កម្លាំង ខ្សោយ
យក នំ ទៅ ឱ្យ បាយ ទឹក ចំណី
គាត់ ហូប មិន កើត មាន ប្រយោជន៍ អ្វី
កូន ប្រុស កូន ស្រី ទិញ ទាំង អស់ គ្នា ។

\+ ម្ហូប សម្ល រ ហូរ ហៀរ ពេញ តុ
តែ គាត់ សំកុក ហូប អ្វី មិន បាន
មាន ប្រយោជន៍ អ្វី សម្រាប់ ខ្លួន ប្រាណ
ហូប ចូល លែង បាន ប្រាណ ស្គម រីង រៃ ។

\+ បំពង់ ក បិទ ជិត លែង ទទួល
លេប អួល ផឹក អួល ដេក ដួល លើ ដី
កូន ស្រែក ហៅ ម៉ែ តែ គាត់ មិន ស្តី
លើក ត្រកង បី ទៅ ដាក់ លើ គ្រែ ។

\+ ព្រឡោ ម៉ែ គាត់ បាត់ ស្មារតី ហើយ
ហៅ គ្មាន ចម្លើយ ឆ្លើយ តប វិញ សោះ
ចំណី ចំណុក នៅ សល់ ទាំង អស់
កូន សែន ស្រណោះ គ្រា អស់ ម្តាយ ហៅ ។

(ចប់)

សូមអនុមោទនា!

## អធិប្បាយ

ម្ហូបអាហារមានរសឆ្ងាញ់ដែលកូនចៅយកមកជូនឪពុកម្ដាយទាំងអស់គ្នានោះ គ្មានប្រយោជន៍អ្វីសម្រាប់គាត់ ដែលកំពុងឈឺពិសាមិនកើតនោះឡើយ។ កូនប្រុសស្រីមេត្តារលឹកគុណ តបគុណ ដល់មាតា បិតាវិញ នៅពេលគាត់នៅហូបបាន នៅចង់ស្លៀកពាក់ល្អ ចង់ធ្វើបុណ្យ។ នៅពេលនោះហើយ ការបរិច្ចាគបច្ច័យ៤ របស់កូនពិតជាមានប្រយោជន៍ និងមានអានិសង្សច្រើនអនេក មិនតែប៉ុណ្ណោះ មានឈ្មោះជាកូនកតញ្ញូទៀតផង ។

# កម្មករល្អរបស់ពុកម៉ែ

(កាព្យរាយ)

+ ជីវិត កម្មករ តស៊ូ ធ្វើ ការ
ប្តូរ យក ដុល្លារ ហាសិប មួយរយ
ខិត ខំ ថែម ម៉ោង យប់ ថ្ងៃ លឿន លយ
មិន ហ៊ាន ខាក ក្រោយ ខ្លាច មិន ហើយ ការ ។

+ កម្មករ រោង ចក្រ ប្រាក់ ខែ បាន តិច
ហើយ ខំ ប្រឹង ល្បិច ផ្ញើ ជូន ពុក ម៉ែ
ចំណែក រូប កូន ទឹក ភ្លើង រាល់ ខែ
ថ្លៃ ផ្ទះ ហូរហែ ដាច់ ខែ គ្មាន សល់ ។

+ កូន រិះ កូន ថាំ ញ៉ាំ សំច័យ ណាស់
សន្សំ ប្រាក់ កាស ទុក ជូន ពុក ម៉ែ
ធ្វើ ការ នៅ ក្រុង ចិត្ត កូន នៅ ស្រែ
នឹក ដល់ ពុក ម៉ែ ដែល គ្មាន ទីពឹង ។

+ មួយ ឆ្នាំ ទម្រាំ បាន ជួប ម៉ែ ម្តង
កូន ឱប ត្រកង នឹក រអ្នក មាន គុណ
ដល់ ពេល ចូល ឆ្នាំ នាំ គ្នា ធ្វើ បុណ្យ
ដូច ព្រះ ករុណា ជន់ ចូល ចិត្ត ម៉ែ ។

\+ ចិត្ត កូន រីករាយ សប្បាយ ដល់ ផ្ទះ
ព្រោះ បាន ជួប ព្រះ អរហន្ត នៃ ខ្ញុំ
បាន ក្រាប សំពះ បាន ថ្វាយ បង្គំ
ជូន បាយ ជូន នំ សូម ខមា ទោស ។

\+ ពុក ម៉ែ ជា ម្លប់ ត្រជាក់ ដល់ កូន
ពុក ម៉ែ ជា ក្បូន ជីដូន ជា ទូក
ចម្លង កូន ចៅ ពី ទឹក ទៅ គោក
ដោយ ការ ឧទ្យោគ[១] លោក ខំ ចិញ្ចឹម ។

\+ ពេល ជួប អ្នក ម្ដាយ ចិត្ត រសាយ អស់
ដូច នៅ លើ កោះ មាន សន្តិភាព
ធ្វើ បុណ្យ ជូន ម្ដាយ ពិត ដូច បាន លាភ
ខ្ញុំ សូម ជម្រាប ជូន ខេមរបុត្រ ។

(ចប់)

សូមអនុមោទនា!

---

(១) ឧទ្យោគ = ឧស្សាហៈ ព្យាយាម សេចក្ដីខំប្រឹង សេចក្ដីខ្មីឃ្មាត

## អធិប្បាយ

កូនអើយ! ទោះបីកូនធ្វើជាកម្មករ កម្មការនី ធ្វើសំណង់ ធ្វើស្រែ ធ្វើចម្ការ ឬ ជាអ្នករត់រ៉ឺម៉កម៉ូតូ ដែលទទួលបានប្រាក់កម្រៃតិចតួចយ៉ាងណាក៏ដោយ តែបើកូនមិនភ្លេចពុកម៉ែទេនោះ គឺពិតជាកូនល្អខ្លាំងណាស់ ។ បើកូនរកបានតិចកូនលៃជូនគាត់ទៅតាមលទ្ធភាពរបស់កូន ដែលអាចជួយបាន នោះពិតជាកូនល្អកម្ររកបានណាស់ ។ កូនសាកគិតទៅមើល កាលកូននៅតូច គាត់បាននំចំណីឆ្ងាញ់ គាត់ពិសាខ្លះទុកឱ្យកូនខ្លះ ជួនកាលគាត់មិនហ៊ានពិសាទេ គឺទុកឱ្យកូនទាំងអស់ ហើយចំណែកគាត់សុខចិត្តអត់ ហើយញញឹមមើលមុខកូនញ៉ាំ ដោយសប្បាយចិត្តទាំងពោះខ្លួនឯងកំពុងតែឃ្លានយ៉ាងណាក៏ដោយ ។ កាលកូននៅតូចពេលហូបបាយម្តងៗ កូនប្រាំទៅប្រាំមួយនាក់ ម៉ែមិនបានពិសារទេ គឺអង្គុយចាំដួសបាយ ដែលកូនហុចចានមកបន្តបន្ទាប់គ្នារហូតនិងចាំដួសសម្ល ថែមសម្លឱ្យកូនទាល់តែកូនបានហូបឆ្អែតគ្រប់ៗគ្នា ទើបម៉ែគាត់ហ៊ានពិសាបាយជាមួយ

សម្ល ដែលនៅសល់ពីកូន គ្មានត្រី គ្មានសាច់ គ្មានបន្លែទេ គឺនៅសល់តែទឹកៗប៉ុណ្ណោះ នេះហើយជាទឹកចិត្តរបស់ម្តាយគ្រប់រូបនៅក្នុងលោកនេះ ។

ពេលណាកូនមានប្តី ប្រពន្ធ ហើយមានកូនពេលនោះហើយ ដែលកូនស្រលាញ់កូនរបស់ខ្លួនយ៉ាងណា ថែរក្សាយ៉ាងម៉េច ដូចជាងូតទឹកឱ្យកូន ស្លៀកពាក់ឱ្យកូន បំបៅដោះកូន បំពេរកូន លួងលោមកូន បញ្ចុកបាយកូន សិតសក់ឱ្យកូន ជុសក្អែលឱ្យកូន ពេលនោះហើយ ទើបយើងដឹងពីទំហំនៃសេចក្តីស្រលាញ់របស់ឪពុកម្តាយ មកលើយើងគ្រប់គ្នាយ៉ាងណា ។ ដូច្នេះ ពេលនេះឱកាសល្អទាន់គាត់នៅមានជីវិត កូនគ្រប់គ្នាគួរតែដឹងគុណតបគុណគាត់វិញទៅតាមលទ្ធភាពដែលកូនមានសព្វថ្ងៃ កុំចាំមាន កុំចាំចូលឆ្នាំ កុំចាំពេលភ្ជុំបិណ្ឌ ត្រូវធ្វើជាប្រចាំរាល់ថ្ងៃ រាល់ខែ រាល់ឆ្នាំ ដូចដែលគាត់ចិញ្ចឹមយើងអញ្ចឹង កុំភ្លេចណាកូនណា! ។

# ពាក្យឪពុកទុកជាមាស

១ កូនអើយពាក្យថា "រួមសុខរួមទុក្ខ"មានពីរគឺ រួមសុខផង និងរួមទុក្ខផង ។ កាលបើកូនបានរៀបការនឹងគ្នាជាប្ដីប្រពន្ធហើយត្រូវចេះស្រលាញ់គ្នា យោគយល់គ្នា អធ្យាស្រ័យដល់គ្នា ប្រសិនបើមាន ទុក្ខទោស គ្រោះថ្នាក់ ឈឺថ្កាត់ កូនត្រូវចេះមើលថែគ្នាឲ្យបានល្អ លើកទឹកចិត្តអ្នកឈឺ ឬ អ្នកគ្រោះថ្នាក់នោះឲ្យមានកម្លាំងចិត្ត ដើម្បីរស់នៅជាមួយគ្នាតទៅទៀត ដោយមិនបោះបង់គ្នាចោលឡើយ ។

២ កូនអើយ ប្ដីប្រពន្ធពេលស្រលាញ់គ្នាគឺ យើងអាចស្រលាញ់ទាំងពីរនាក់បាន ពោលគឺ ស្រលាញ់គ្នាទៅវិញទៅមក ប៉ុន្តែបើខឹងវិញសូមកូនកុំខឹងទាំងពីរនាក់គឺខឹងទៅវិញទៅមកឲ្យសោះ បើប្ដីខឹង ប្រពន្ធអត់ ពោលគឺ កុំខឹងតបវិញ ឬ បើប្រពន្ធខឹង ប្ដីអត់ ពោលគឺ កុំខឹងតបវិញអី បើកូនទាំងពីរនាក់ធ្វើបានដូចនេះវាអាចកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារបានកម្រិតខ្ពស់ ប៉ុន្តែយក

ល្អបំផុតនោះគឺ ព្យាយាមទប់កំហឹង ឬ រំលត់កំហឹង ដោយប្រើ សំរឹទ្ធិ ស័ក្តិសិទ្ធិ នៅក្នុងគ្រួសារគឺ ទឹកចិត្ត មេត្តា ករុណា នេះឯង ។

៣. កូនអើយ ជីវិត ប្តីប្រពន្ធ ក្រោយពីម៉ែទុកឪពុកដាក់រៀបការឲ្យរួចហើយគឺ ត្រូវចេះគោរពគ្នាទៅវិញទៅមក ហើយចេះថៃរក្សា និងស្រលាញ់គ្នាប្រៀបដូចជាមាស ព្រោះមាសកាន់តែចាស់កាន់តែល្អ ទើបគ្រួសារមានសេចក្តីសុខកូនចៅបានជួបមុខរហូតដល់ចាស់ ។

៤. កូនអើយ មនុស្សយើងស្រស់ស្អាតតែនៅក្មេងវ័យទេ កាលណាចម្រើនវ័យកាន់តែចាស់កាន់តែអាក្រក់ ព្រោះត្រូវជ្រីវជ្រួញ ស្គូវសក់ បាក់ធ្មេញ គឺមានតែទឹកចិត្ត មេត្តា ករុណា ចំពោះគ្នានឹងគ្នាប៉ុណ្ណោះដែលមិនចេះចាស់ ហើយមើលទៅមិនឃើញអាក្រក់ទើបអាចរក្សាគ្នា នៅជាមួយគ្នា រហូតដល់ចាស់រៀងៗខ្លួនបានដោយសុភមង្គល ។

៥. កូនអើយ កាន់តែប្រើកាន់តែចេះ គឺចំណេះវិជ្ជា កាន់តែប្រើកាន់តែមានតម្លៃគឺ សេចក្ដីល្អ កាន់តែប្រើកាន់តែមានពន្លឺគឺ បញ្ញា កាន់តែរក្សាកាន់តែល្អគឺ សីល កាន់តែប្រព្រឹត្តកាន់តែប្រសើរគឺ សុចរិត កាន់តែប្រិតប្រៀងកាន់តែបវរគឺ វាចាការពិត កាន់តែធ្វើកាន់តែចម្រើនគឺបុណ្យ កាន់តែឲ្យកាន់តែមានគឺ ទាន កាន់តែរៀនកាន់តែចេះ និងកាន់តែយល់អំពីជីវិតគឺ ព្រះធម៌ ។

៦. អំពើល្អក្រដូចច្រាស់ទឹក ប្រឹងល្ងាចប្រឹងព្រឹកកុំបណ្ដោយ ទោះទាំងទឹកភ្នែកជ្រែកក៏ដោយ ថ្ងៃក្រោយនឹងបានសុខសាន្តទៅអើយ ។



បណ្ឌិតពោលថា មាតាបិតា
មានគុណខ្លាំងណាស់ គុណនោះសែនធំ
ជាងសុវណ្ណគិរី ធ្ងន់ដូចធរណី
កាត់ថ្លៃមិនបាន ។
បើយើងរាប់គុណ តាំងពីទម្ងន់
មានគភ៌ក្នុងផ្ទៃ ម្ដាយចាញ់ខ្លាំងណាស់
អស់កម្លាំងល្ហិតល្ហៃ ទន់ជើងទន់ដៃ
ហូបអ្វីមិនកើត ។